មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក

**រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២៥**

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ គឺជាទិវាសេរីភាពសារព័ត៌មានពិភពលោក។ ទិវានេះប្រារព្ធឡើងដើម្បីគោរពដល់តួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មាន ក្នុងការនាំយកព័ត៌មានដែលត្រឹមត្រូវ និងអាចទុកចិត្តបានដល់សាធារណជន ពេលខ្លះពួកគេប្រឈមនឹងសុវត្ថិភាពផ្ទាល់ខ្លួន និងជាការរំលឹកអំពីសារៈសំខាន់នៃសេរីភាពសារព័ត៌មានក្នុងការលើកកម្ពស់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។ ទិវានេះក៏ជាការរំលឹកដល់រដ្ឋាភិបាលនៅជុំវិញពិភពលោកឱ្យបង្កើននូវបរិយាកាសដែលសេរីភាពសារព័ត៌មានទទួលការការពារ ដែលផ្តល់អំណាច និងអាចឱ្យប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យបំពេញតួនាទីដ៏មានសារៈសំខាន់របស់ខ្លួនដោយមិនមានការបៀតបៀន។

ជាការគួរឱ្យសោកស្តាយ ម.ស.ម.ក សង្កេតឃើញថាប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅកម្ពុជានៅតែបន្តប្រឈមនឹងឧបសគ្គជាច្រើននៅក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនដោយសេរី និងគ្មានការដាក់កំហិតសិទ្ធិរបស់ខ្លួនឯង។ ការបន្តបៀតបៀនទៅលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលជាសិទ្ធិមូលដ្ឋានរបស់ពួកគេនៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជា ដែលធ្វើឱ្យចំនួនប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកាន់តែរួមតូចក្នុងការផ្តល់ជាជម្រើសនៃប្រភពព័ត៌មាន និងដំណឹង។

នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤ អ្នកសារព័ត៌មានចំនួន ១៧ នាក់រងយាយីតាមប្រព័ន្ធតុលាការដោយសារតែការរាយការណ៍ព័ត៌មានរបស់ខ្លួន និងអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន ៣ ត្រូវបានដកហូត។ នៅក្នុងសន្ទស្សន៍នៃសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៤ បាន វាយតម្លៃថាប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១៥១ ក្នុងចំណោមប្រទេសចំនួន ១៨០ ដែលបានបង្ហាញពីការធ្លាក់ចុះបើប្រៀបធៀបជាមួយទិន្នន័យពីឆ្នាំមុនៗ។ អាជ្ញាធរកម្ពុជាខកខានក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពឯករាជ្យ និងតម្លាភាពចំពោះអ្នកសារព័ត៌មានចំនួន ១៥ រូបដែលត្រូវបានសម្លាប់ក្នុងអំឡុងពេលពីរទសវត្សចុងក្រោយនេះ។ ជាលទ្ធផល ជនល្មើសមិនទាន់ត្រូវចាប់មកផ្តន្ទាទោសឱ្យស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិនៅឡើយ។

នៅក្នុងបរិយាកាសដែលប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាកំពុងបន្តធ្លាក់ចុះ ទិវានេះកាន់តែមានសារៈសំខាន់ដើម្បីបង្ហាញថា លទ្ធិប្រជាធិបតេយ្យត្រូវការគាំទ្រដោយប្រព័ន្ធផ្សព្វផ្សាយដែលសេរី និងឯករាជ្យជាចាំបាច់។

ដើម្បីប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកនៅឆ្នាំនេះ ម.ស.ម.ក នឹងរៀបចំ យុទ្ធនាការតាមអនឡាញដើម្បីផ្តល់ព័ត៌មានដល់សាធារណជនអំពីទិវានេះ និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃសេរីភាព

ខាងការបញ្ចេញមតិ និងតួនាទីរបស់អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងសង្គមប្រជាធិបតេយ្យ។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់សកម្មភាពដូចខាងក្រោម៖

- នៅថ្ងៃទី២៩ ខែមេសា ម.ស.ម.ក នឹងចេញផ្សាយឡើងវិញនូវកម្រងសំណួរនៅលើប្រព័ន្ធអនឡាញស្តីពីសេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។
- នៅថ្ងៃទី០២ ខែឧសភា ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុផ្សាយផ្ទាល់លើប្រធានបទ "ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា"។
- នៅថ្ងៃទី០៥ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយនូវបណ្ណព័ត៌មានស្តីពីស្ថានភាពនៃសេរីភាពសារព័ត៌មាននៅកម្ពុជា។
- នៅថ្ងៃទី០៦ និងថ្ងៃទី ០៨ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយនូវសម្រង់ខ្លឹមសារនៃកិច្ចពិភាក្សាវិទ្យុដែលរៀបចំឡើងថ្ងៃទី០២ ខែឧសភា។
- នៅថ្ងៃទី១២ និងថ្ងៃទី១៤ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយនូវវីដេអូចំនួនពីរ(១) លម្អប្រព័ន្ធផ្សព្វផ្សាយ (២) លើកកម្ពស់សេរីភាពព័ត៌មានក្នុងបរិបទថ្មីៗ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ហួន ផន អ្នកសម្របសម្រួលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា នៃម.ស.ម.ក តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ។

<u>**ចប់**</u>

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និងជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសបែន (Brisbane) នៃប្រទេសអូស្ត្រាលី។